អន្តរប្ញូរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បុគ្គលត្រូវធ្វើអំពើល្អគ្រប់វ័យ តាំងពីក្មេងរហូតចាស់ស្លាប់ ។

website: www.hoksavann.org

ថ្ងៃទី២១ មេសា ២០០៨



តាមពាក្យចាស់បូរាណខ្មែរថា បុគ្គលត្រូវធ្វើកិច្ចការស្រប ទៅតាមវ័យរបស់ខ្លួន ។ ក្នុងបឋមវ័យ គឺវ័យក្មេងត្រូវខំសិក្សា រៀនសូត្រ ។ ក្នុងមជ្ឈិមវ័យ គឺវ័យកណ្តាល ត្រូវរៀបចំឲ្យមាន គូស្រករ ហើយខំប្រឹងប្រែងធ្វើការរកស៊ីចិញ្ចឹមជីវិតរបស់ខ្លួន។ ក្នុងបច្ឆិមវ័យ គឺវ័យខាងចុងបំផុត ជាវ័យចាស់ ត្រូវស្វែងរក ធម៌ដោយខំធ្វើទានរក្សាសីលចំរើនមេត្តាភាវនាស្តាប់ព្រះសង្ឃ សំដែងធម៌ទេសនា ។ ការបំពេញការងារស្របទៅតាមវ័យដូ ច្នេះជាការត្រឹមត្រូវបានមួយផ្នែកហើយ ប៉ុន្តែអំពើល្អត្រូវធ្វើ គ្រប់វ័យ ។ សេចក្តីថា អំពើល្អជាគុណធម៌របស់មនុស្ស ត្រូវឲ្យមានគ្រប់វ័យទាំងបី ។ ជី វិតរបស់មនុស្សពុំទៀង បុគ្គលខ្លះស្លាប់ពីក្មេង ឬពាក់កណ្តាលអាយុ ពុំមានជីវិតរស់នៅ រហូតដល់ចាស់ ដើម្បីបំពេញសេចក្តីល្អ មានការធ្វើទានរក្សាសីលជាដើមឡើយ ។ ដូ-ច្នេះតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បុគ្គលត្រូវសាងសេចក្តីល្អគ្រប់វ័យ គឺត្រូវធ្វើសេ ចក្តីល្អតាំងពីក្មេងមក ។ បើបុគ្គលរស់នៅរហូតដល់ចាស់ជរា កាលពីក្មេងនិងពាក់កណ្តា លអាយុមិនបានបំពេញសេចក្តីល្អ លុះដល់ចាស់ជរាទើបបំពេញសេចក្តីល្អ នោះសេចក្តី អាក្រក់គេបានប្រព្រឹត្តយូរជាងអំពើល្អ បើតាមន័យនៃពាក្យចាស់បូរាណនេះ ។ ប៉ុន្តែបើ អនុវត្តតាមធម៌ព្រះពុទ្ធវិញ បុគ្គលកើតឡើងដឹងក្តីត្រូវសាងសេចក្តីល្អ តាំងពីក្មេងរហូតដ ល់ចាស់ស្លាប់ បើបុគ្គលក្នុងវ័យណាមួយ ក៏មានកុសលធម៌ជាប់តាមខ្លួនទៅ ។

កុសលធម៌មិនទំនាស់ដល់បុគ្គលក្នុងវ័យណាមួយឡើយ ។ ដូចកុមារក្នុងបឋមវ័យ ដែលកំពុងសិក្សារៀនសូត្រ ត្រូវមានចរិយាល្អ មិនប្រព្រឹត្តធ្វើអំពើពាលាអាវ៉ាសែ មិនប្រ ព្រឹត្តអំពើអបាយមុខផ្សេងៗ ដូចល្បែងស្រី ល្បែងស្រា ល្បែងស៊ីសងជាដើម ទើបការ

សិក្សាបានសំរេចជោគជ័យ ។ ដូច្នេះអំពើល្អនេះហើយ ដែលជួយការសិក្សារបស់យុវវ័
យបានចំរើនលូតលាស់ ។ កុមារា កុមារី យុវជន និងយុវនារីអាចកាន់សីល៥ មានមិន
សម្លាប់មនុស្សសត្វ មិនកាន់យកទ្រព្យសម្បត្តិដែលគេមិនបានឲ្យជាដើម ហើយត្រូវមាន
សុជីវធម៌គោរពចាស់ព្រឹទ្ធាចារ្យ គោរពមាតាបិតា គោរពអ្នកមានគុណ គោរពគ្រូ គោរព
ច្បាប់សាលា ទើបជាសិស្សនិងនិស្សិតល្អ ដែលជាធនធានដ៏ប្រសើររបស់ប្រទេស ។ ដូ
ច្នេះគុណធម៌ជាធាតុត្រូវបណ្តុះឲ្យកើតមានតាំងពីកុមារភាព ព្រោះសេចក្តីល្អរបស់បុគ្គល
មួយរូបៗ ត្រូវអប់រំប្រើពេលយូរ បើវ័យចាស់ទើបសាងសេចក្តីល្អពុំបានគ្រប់គ្រាន់ឡើយ
ហើយវ័យដែលសាងសង្គម គឺវ័យនៅក្មេង ជាវ័យមានកម្លាំងកាយ និងកម្លាំងបញ្ញាស្មារ
តីមាំមួន ដូច្នេះត្រូវតែបណ្តុះយុវជនឲ្យមានវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិផ្នែកគុណធម៌
មានសីលធម៌ជាដើមឲ្យបានខ្ពង់ខ្ពស់ ។ ចំណែកពាក្យថា ក្នុងមជ្ឈិមវ័យត្រូវខិតខំធ្វើការ
ចិញ្ចឹមជីវិតនោះ ក៏ពុំអាចលះបង់អំពើល្អបានឡើយ ដូចព្រះពុទ្ធសំដែងថា ត្រូវធ្វើការរក
ស៊ីប្រកបដោយសម្មាអាជីវោ គឺចិញ្ចឹមជីវិតដ៏ត្រឹមត្រូវ ជៀសវាងនូវជំនួញ៥ប្រការ មាន
ជួញដូរមនុស្ស ជួញគ្រឿងសាស្ត្រាវុធ ដែលនាំឲ្យមនុស្សយកទៅសម្លាប់គ្នាជាដើម ។ អ្ន
ករាជការគ្រប់តំណែង ត្រូវបំពេញមុខងាររបស់ខ្លួនឲ្យបានត្រឹមត្រូវ កុំស៊ីសំណូក ពុករលួ
យ ជិះជាន់ប្រជាពលរដ្ឋរបស់ខ្លួនជាដើម ។

ដូចពោលមកហើយ បុរាណសុភាសិតនិងពុទ្ធភាសិតមានលក្ខណៈខុសគ្នា ។ បុរាណ
សុភាសិតជាពាក្យខ្មែរបូរាណបានពោល ពុំត្រឹមត្រូវឥតខ្ចោះនោះឡើយ ដូចពាក្យក្នុងប្រ
ធានបទនេះថា បុគ្គលត្រូវបំពេញការងារស្របតាមវ័យរបស់ខ្លួន ប៉ុន្តែមិនបានបញ្ជាក់ឲ្យ
ច្បាស់ថា ក្នុងវ័យនីមួយៗ ត្រូវបណ្តុះគុណធម៌ មានសីលធម៌ជាដើមផងទេ ។ ចំណែក
ពុទ្ធភាសិតជាសច្ចៈសាកលដូចពាក្យថា មនុស្សគ្រប់វ័យត្រូវសាងសេចក្តីល្អ ហើយសេច
ក្តីល្អ ដូចសីលសម្មាធិបញ្ញា បើគ្រប់ជនជាតិយកទៅប្រតិបត្តិតាម នឹងមានភាពល្អដូចគ្នា
។ ដូច្នេះត្រូវគោរពតាមពាក្យចាស់បូរាណខ្មែរនេះចុះ ប៉ុន្តែសិស្សក្នុងបឋមវ័យ ត្រូវបន្ថែម
វិជ្ជាចាំបាច់មួយទៀត គឺវិជ្ជាសីលធម៌ ដោយតម្រូវឲ្យអនុវត្តតែម្តង ព្រោះសីលធម៌ជាគុ
ណសម្បត្តិរបស់មនុស្សគ្រប់រូបគ្រប់វ័យ ។ ចំណែកបុគ្គលក្នុងមជ្ឈិមវ័យ ដែលធ្វើការរក
ស៊ីនិងធ្វើរាជការ ត្រូវបន្ថែមចរិយាសម្បត្តិមួយទៀត គឺធ្វើការរកស៊ីឲ្យត្រឹមត្រូវ អ្នករាជ
ការត្រូវបំពេញការងារឲ្យបានត្រឹមត្រូវតាមមុខងាររបស់ខ្លួន ។ ចំណែកមនុស្សចាស់ដែល
ជាវ័យទីបំផុត ក៏គួរស្វែងរកកុសលធម៌ ដើម្បីជាទីពឹងក្នុងលោកខាងមុខ ព្រោះអ្វីៗត្រូវ
ទុកចោលទាំងអស់ មានតែបុណ្យកុសលទេ ជាអារិយទ្រព្យជាប់តាមខ្លួនទៅ ។៚